ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៥៥ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការតម្លើងសាលានាយទាហានថ្នាក់ពល ទៅជាសាលានាយទាហានសកម្ម មានកំរិតស្មើគ្រឹះស្ថានឧត្តមសិក្សា

# រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត ១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី ។
- បានឃើញព្រះរាជក្រមលេខ នស/រកម ០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំយុវជន និង កីឡា ។
- បានឃើញព្រះរាជក្រមលេខ ជស/រកម១១៩៧/០៥ ចុះថ្ងៃទី ០៦ ខែវិច្ឆិកា ឆ្នាំ ១៩៩៧ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ ។
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ .បក ចុះថ្ងៃទី ២៣ ខែមីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងអប់រំយុវជន និង កីឡា ។
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ .បក ចុះថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ ។

# សំ  រេ  ច

**មាត្រា១ ._**

តម្លើងសាលានាយទាហានត្លាតពង ទៅជាសាលានាយទាហានសកម្ម មានកំរិតស្មើនឹងគ្រឹះស្ថានឧត្តមសិក្សា ។ សាលានាយទាហានសកម្ម សរសេរអក្សរកាត់ថា **ស.ន.ស** ។

**មាត្រា២._**

សាលា នាយទាហានសកម្ម ស្ថិតនៅក្រោមការគ្រប់គ្រង របស់ក្រសួងការពារជាតិ ។

**មាត្រា៣._**

សាលានាយទាហានសកម្ម មានភារកិច្ចបណ្តុះបណ្តាល នាយទាហានសកម្ម តាមខ្លឹមសារ នៃកម្មវិធីបណ្តុះបណ្តាលរយៈពេល៤ឆ្នាំ អំពីវិទ្យាសាស្ត្រយោធា និង ចំណេះដឹងទូទៅ ។ ក្រៅពីនេះ សាលានាយទាហានសកម្ម មានភារកិច្ចបណ្តុះបណ្តាលអំពីមុខវិជ្ជាផ្សេងបន្ថែមទៀត តាមការណែនាំរបស់ ក្រសួងការពារជាតិ ។

**មាត្រា៤._**

ល័ក្ខខ័ណ្ឌនៃការជ្រើសរើស សិស្ស និស្សិត ទាំងពីរភេទ ឱ្យចូលបណ្តុះបណ្តាលនៅក្នុង សាលានាយទាហានសកម្ម ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងការពារជាតិ ។

**មាត្រា៥._**

សញ្ញាបត្របញ្ចប់ការសិក្សានាយទាហានសកម្ម មានតម្លៃសមមូលបរិញ្ញាបត្រ នៃគ្រឹះស្ថានឧត្តមសិក្សា ។ បរិញ្ញាប័ត្រនេះត្រូវផ្តល់ចំពោះ នាយទាហានសកម្មទាំងឡាយណាដែលបានឆ្លងកាត់ការបណ្តុះបណ្តាល រយៈពេលយ៉ាងតិច៤ឆ្នាំឡើងទៅ និងបានប្រលងបញ្ចប់ការសិក្សាដោយជោគជ័យ ។

**មាត្រា៦._**

សិទ្ធិសំរេចនៃការចេញបរិញ្ញាប័ត្រនាយទាហានសកម្មគឺជាបន្ទុករួមរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ និង រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា ។

**មាត្រា៧.—**

ក្រសួងការពារជាតិ និង ក្រសួងអប់រំយុវជន និងកីឡា ត្រូវសហការរៀបចំកម្មវិធីបណ្តុះបណ្តាល និង គ្រូបង្រៀនឱ្យឆ្លើយតបនឹងសំណូមពរ ភារកិច្ច នៃការកសាងជួរនាយទាហានសកម្មក្នុងកង យោធពលខេមរភូមិន្ទ។

**មាត្រា៨.—**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួង អប់រំយុវជននិងកីឡា អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀង១ខ្លួន ។

**មាត្រា៩.—**

អនុក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី.២៦.....ខែ.មិថុនា..ឆ្នាំ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួង ព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- ខុទ្ទកាល័យ សម្តេច នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៨
- ឯកសារ-កាលប្បវត្តិ